# II – រាជរដ្ឋាភិបាល

## ១_អនុក្រឹត្យ

### អនុក្រឹត្យ លេខ ៦៥ អនក្រ.បក

### ស្តីអំពីការបង្កើតវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល

– បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

– បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២

– បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

– បានឃើញព្រះរាជក្រមលេខ ០២ នស ៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

– បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤/៨៣ ចុះថ្ងៃទី២៤ ខែ តុលា ឆ្នាំ ១៩៩៤ និង ព្រះរាជក្រឹត្យ នស.រកត ១០៩៤/៩០ ចុះថ្ងៃទី៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

– បានឃើញព្រះរាជក្រមលេខ នស.រកម /០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

– បានឃើញព្រះរាជក្រមលេខ នស.រកម /០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

– បានឃើញព្រះរាជក្រឹត្យលេខ ជស.រកត /០៨៩៧/១៤៧ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

– តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានការអនុម័តរបស់គណៈរដ្ឋមន្ត្រី នាសម័យប្រជុំ ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ១៩៩៧

## សំរេច

## ជំពូកទី ១

## បទបញ្ញត្តិទូទៅ

**មាត្រា១.-** វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ហៅកាត់ថា (**វសកក**) ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ស្ថិតនៅក្រោមបទបញ្ញត្តិ នៃអនុក្រឹត្យនេះ ព្រមទាំងបទបញ្ជាផ្ទៃក្នុងមួយ និងបទបញ្ញត្តិពាក់ព័ន្ធដទៃទៀត នាថ្ងៃក្រោយ ។

**មាត្រា២.-** **វសកក** មាននីតិបុគ្គលភាព និង ស្វ័យភាពហិរញ្ញវត្ថុ ។

**មាត្រា៣.-**

៣.១. ក្នុងឋានៈជាស្ថាប័នសាធារណៈ **វសកក** ទទួលពីរដ្ឋនូវអំណាច និងភារកិច្ចទាំងឡាយ ដើម្បីបំពេញបេសកកម្ម ស្របតាមកម្មវត្ថុរបស់ខ្លួន ។

៣.២. **វសកក** មានភារកិច្ចដូចតទៅ :

-ដឹកនាំ និង សំរេចរាល់សកម្មភាពស្រាវជ្រាវ និងពិសោធន៍ សំដៅជំរុញការអភិវឌ្ឍន៍លើគ្រប់ផ្នែកនៃដំណាំកៅស៊ូទូទៅ ។

-ចូលរួមក្នុងរាល់សកម្មភាពនៃការជំរុញ ផ្នែកបច្ចេកទេសសុវត្ថិភាពនៃគុណភាពកៅស៊ូ និង តម្លៃផលិតកម្ម ។

៣.៣. ដើម្បីអនុវត្តភារកិច្ចខាងលើនេះ **វសកក** មានកាតព្វកិច្ច :

-ទ្រទ្រង់ដល់ការអនុវត្តន៍រាល់កម្មវិធីអភិវឌ្ឍដំណាំកៅស៊ូ តាមការសិក្សាអំពីលក្ខណៈវិនិច្ឆ័យ ការតាមដាន និងវាយតម្លៃលទ្ធផល តាមការរៀបចំសិក្ខាសាលាឯកសារ ផ្នែកបច្ចេកទេសនិងហិរញ្ញវត្ថុ និងតាមការធ្វើវិញ្ញាបនកម្មច្បាប់ពូជ ។

-ចាត់ចែងផ្តល់ពូជល្អៗ តាមការបញ្ចូល សាកល្បង បង្កើត បង្កើន និងការផ្សព្វផ្សាយពូជ ។

- ចូលរួមក្នុងការធ្វើអោយមានតម្លៃនូវគុណភាពកៅស៊ូ តាមការគ្រប់គ្រងមន្ទីរពិសោធន៍ជាតិ ផ្អែកយថាប្រភេទ និងតាមការបង្កើតបទដ្ឋានស្តីពីគុណភាព ។
- ចាត់ចែងមធ្យោបាយធ្វើលក្ខណៈវិនិច្ឆ័យ និង វិភាគ ។
- ចូលរួមក្នុងសកម្មភាព ក្នុងការបណ្តុះបណ្តាល ពត៌មាន ការផ្សព្វផ្សាយ និងការផ្ទេរបច្ចេកវិជ្ជាថ្មី ។
- និងជាទូទៅ តាមការផ្តួចផ្តើមគំនិតរបស់ខ្លួនផ្ទាល់ ឬតាមសំណើរបស់ដៃគូក្នុងប្រទេស និងក្រៅប្រទេស និងចាត់ចែងគ្រប់សកម្មភាពដែលជាអត្ថប្រយោជន៍ ដល់ការអភិវឌ្ឍន៍ប្រព័ន្ធកៅស៊ូ ព្រមទាំងកែលំអនូវការយល់ដឹងក្នុងវិស័យនេះផង ។

## ជំពូកទី ២

## ការដឹកនាំ និងការគ្រប់គ្រង

### ផ្នែកទី ១

### អង្គការសំរេចរបស់វិទ្យាស្ថាន

**មាត្រា៤.–** **វសកក** ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាលមួយ ដែលមានសិទ្ធិយ៉ាងធំទូលាយ ដើម្បីបំពេញបេសកកម្មក្នុងនាម **វសកក** ក្នុងក្របខ័ណ្ឌនៃបទបញ្ញត្តិ នៃអនុក្រឹត្យនេះ និងបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ។

**មាត្រា៥.–**

៥.១. ក្រុមប្រឹក្សាភិបាល មានសមាជិក ៧រូប ដែលមានសមាសភាពដូចតទៅ :

| | |
|---|---|
| – តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | ប្រធាន |
| – តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| – ប្រធានអគ្គនាយកដ្ឋានចំការកៅស៊ូ | សមាជិកស្វ័យប្រវត្តិ |
| – នាយកវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | សមាជិកស្វ័យប្រវត្តិ |

-តំណាងអ្នកដាំកៅស៊ូ ២ នាក់ សមាជិក

-តំណាងបុគ្គលិកវិទ្យាស្ថាន សមាជិកស្ម័យប្រវត្តិ

**៥.២.** ប្រធាន និងសមាជិកក្រុមប្រឹក្សាភិបាល ត្រូវតែងតាំងដោយអនុក្រឹត្យមួយ សំរាប់អាណត្តិ ៣ឆ្នាំ ។ អាណត្តិនេះអាចបញ្ចប់បានគ្រប់ពេលវេលា ដោយអនុក្រឹត្យ តាមសំណើនៃក្រសួង ឬអាជ្ញាធរដែលខ្លួនតំណាងអោយ ។

**មាត្រា៦.-**

**៦.១.** ប្រធានក្រុមប្រឹក្សាភិបាលមានតួនាទីកោះប្រជុំ និងកំណត់របៀបវារៈ នៃអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាល ព្រមទាំងធានារបៀបរៀបរយ នៃកិច្ចប្រជុំនេះអោយបានប្រសើរ ។

**៦.២.** បទបញ្ជាផ្ទៃក្នុងនៃ **ទសកក** អាចអនុញ្ញាតអោយក្រុមប្រឹក្សាភិបាលអញ្ជើញឥស្សរជន នៅក្នុងឬក្រៅវិទ្យាស្ថាននេះ ដែលមានបទពិសោធន៍លើវិស័យកៅស៊ូផ្នែកកសិកម្ម រុក្ខកម្ម ឧស្សាហកម្ម និងសេដ្ឋកិច្ចកៅស៊ូ ចូលរួមក្នុងអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាល។ ឥស្សរជនទាំងនេះមានសិទ្ធិផ្តល់មតិ តែពុំមានសិទ្ធិបោះឆ្នោតឡើយ។

**មាត្រា៧.-** ក្រុមប្រឹក្សាភិបាលមានបេសកកម្មដឹកនាំ តំរង់ទិសដៅ និងធ្វើការត្រួតពិនិត្យលើដំណើរការរបស់វិទ្យាស្ថាន ។

ក្នុងក្របខ័ណ្ឌនៃបេសកកម្មនេះ ក្រុមប្រឹក្សាភិបាលត្រូវ :

-សំរេចផែនការអភិវឌ្ឍន៍នៃ **ទសកក** ស្របតាមទិសដៅកំណត់របស់រដ្ឋាភិបាល ។

-សំរេចលើចំណូល និងចំណាយជាប្រចាំ ព្រមទាំងទុនក្នុងថវិកាប្រចាំឆ្នាំរបស់ **ទសកក** ។

-ពិនិត្យសំរេចលើរបាយការណ៍គ្រប់គ្រង និងលើគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ ។

-កំណត់ការរៀបចំរចនាសម្ព័ន្ធ ព្រមទាំងការបែងចែកភារកិច្ចជាទូទៅ ដល់អង្គភាពឯទៀតក្រោមឱវាទ ។

-កំណត់នូវរបបជ្រើសរើស ការតម្លើងឋានន្តរសក្តិ ការផ្តល់លាភការដល់បុគ្គលិក **ទសកក** ដោយមិនប៉ះពាល់ដល់បទបញ្ញត្តិច្បាប់ ឬបទបញ្ជាផ្ទៃក្នុង ដែលអនុវត្តចំពោះភ្នាក់ងាររបស់មុខងារសាធារណៈ ។

-សំរេចលើក្របខ័ណ្ឌចំនួនបុគ្គលិក ដែលអនុញ្ញាតអោយ **ទសកក** ។

-សំរេចលើអនុសញ្ញា កិច្ចសន្យា និងលទ្ធកម្មទាំងឡាយដែលស្របតាម និយាមចែង ក្នុងបទបញ្ជាផ្ទៃក្នុង ឬបទបញ្ញត្តិទាំងឡាយ ដែលសំរេចដោយក្រុមប្រឹក្សាភិបាល ។
-តាមចន្លោះពេលទៀងទាត់ វាយតម្លៃ ក៏រិតលទ្ធផលសំរេចបាននូវគោលដៅ កំណត់ដោយ **ទសកក** ហើយកំណត់នូវវិធានការកែតម្រូវដើម្បីអនុវត្ត ។

**មាត្រា៩.-**

៩.១. ក្រុមប្រឹក្សាភិបាលនៃ **ទសកក** ត្រូវធ្វើការប្រជុំនៅពេលណា ដែលផលប្រយោជន៍របស់ **ទសកក** តម្រូវនិងត្រូវធ្វើការយ៉ាងតិចមួយឆមាសម្តង តាមការអញ្ជើញរបស់ប្រធាន ឬតាមសំណើរបស់សមាជិក៣នាក់ ឬតាមការស្នើសុំពីនាយកនៃ **ទសកក** ។ របៀបវារៈ ព្រមទាំងឯកសារទាំងឡាយត្រូវផ្ញើជូនគ្រប់សមាជិកនៃក្រុមប្រឹក្សាភិបាល និងគ្រប់ក្រសួងពាក់ព័ន្ធ ដែលមានចែងក្នុងអនុក្រឹត្យនេះ យ៉ាងតិច១០ថ្ងៃ មុនថ្ងៃប្រជុំ ។

៩.២. ការប្រជុំនៃក្រុមប្រឹក្សាភិបាល អាចទទួលយកជាការបាន លុះត្រាតែសមាជិកវត្តមាន មានចំនួន ៤នាក់យ៉ាងតិច នៃបណ្តាសមាជិកទាំងអស់ ។ សមាជិកអវត្តមានគ្មានសិទ្ធិបញ្ជូនតំណាងអោយមកប្រជុំជំនួសខ្លួនបានឡើយ។ ប្រសិនបើសម្លេងកូរ៉ុមមិនគ្រប់ចំនួនទេ ក្រុមប្រឹក្សាភិបាលត្រូវកោះប្រជុំម្តងទៀត យ៉ាងយូរ៨ថ្ងៃក្រោយថ្ងៃប្រជុំលើកមុន ហើយសេចក្តីសំរេចប្រជុំលើកក្រោយនេះ មិនទាមទារសម្លេងកូរ៉ុមទេ ។ សមាជិកវត្តមានត្រូវចុះហត្ថលេខាលើបញ្ជីវត្តមានមួយ ។ សេចក្តីសំរេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាលអាចយកជាការបាន លុះត្រាតែមានការអនុម័តដោយសំលេងភាគច្រើន នៃសមាជិកវត្តមាន ។ ក្នុងករណីមានការចែកសំលេងនោះ ប្រធានក្រុមប្រឹក្សាភិបាល ត្រូវមានឧត្តមានុភាព ។

៩.៣. សេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាល ត្រូវកត់ត្រាក្នុងបញ្ជីពិសេសមួយ តំកល់ទុកនៅទីស្នាក់ការរបស់វិទ្យាស្ថាន និងត្រូវចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាភិបាល និងនាយក **ទសកក** ដែលមានតួនាទីជាលេខានៃសម័យប្រជុំ ។ កំណត់ហេតុនេះត្រូវបង្ហាញនូវអត្ថន័យ នៃការពិភាក្សាអោយបានច្បាស់លាស់ និងត្រូវផ្ញើជូនគ្រប់សមាជិកនិងក្រសួងពាក់ព័ន្ធទាំងឡាយយ៉ាងយូរ ១០ថ្ងៃក្រោយពេលប្រជុំ ។

## ផ្នែកទី ២

## អង្គការប្រតិបត្តិរបស់វិទ្យាស្ថាន

**មាត្រា១០.–** **វសកក** ត្រូវគ្រប់គ្រងដោយនាយកមួយរូប ដែលតែងតាំងដោយអនុក្រឹត្យតាមសំណើ របស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ។ នាយកអាចត្រូវបានបញ្ឈប់គ្រប់ពេលវេលា ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា១១.–**

**១១.១.** នាយក **វសកក** មានសិទ្ធិពេញលេញ ដើម្បីគ្រប់គ្រង **វសកក** លើកលែងតែសិទ្ធិដែលមានចែងក្នុងច្បាប់ និងបទបញ្ជាផ្ទៃក្នុង ដែលជាសមត្ថកិច្ចផ្ទាល់របស់ក្រុមប្រឹក្សាភិបាល ។

នាយក :

- រៀបចំ និងចូលរួមក្នុងអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាល ។
- ទទួលបន្ទុកអនុវត្តសេចក្ដីសំរេចទាំងឡាយ របស់ក្រុមប្រឹក្សាភិបាល ព្រមទាំងដាក់អោយដំណើរការនូវនយោបាយ ដែលកំណត់ដោយក្រុមប្រឹក្សានេះ ។
- រៀបចំថវិកាប្រចាំឆ្នាំសំរាប់ **វសកក** ហើយដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យសំរេច ។
- ធ្វើរបាយការណ៍ប្រចាំឆ្នាំលើរាល់សកម្មភាព ត្រួតពិនិត្យលើគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ ហើយដាក់ឯកសារទាំងនេះជូនក្រុមប្រឹក្សាភិបាលពិនិត្យសំរេច ។
- ធ្វើការបញ្ជាក់ក្នុងករណីចាំបាច់ លើភារកិច្ចរបស់បណ្ដាអង្គភាពក្រោមឱវាទ ។
- បំពេញរាល់មុខតំណែងរបស់ **វសកក** ក្នុងក៏រិតក្របខ័ណ្ឌចំនួនបុគ្គលិក កំណត់ដោយក្រុមប្រឹក្សាភិបាល ព្រមទាំងគោរពតាមវិធាន ស្ដីពីការគ្រប់គ្រងបុគ្គលិក ។
- បំពេញតួនាទីជាឋានានុក្រមថ្នាក់លើ ចំពោះបុគ្គលិកទាំងមូលនៃ **វសកក** ។
- ចុះកិច្ចសន្យា និងចុះហត្ថលេខា លើអនុសញ្ញាទាំងឡាយ ដែលស្របតាមសេចក្ដីសំរេចរបស់ក្រុមប្រឹក្សាភិបាល តាមការបែងចែកសិទ្ធិអំណាច និងតាមបទបញ្ជាផ្ទៃក្នុង ព្រមទាំងបទបញ្ញត្តិដទៃទៀត ស្ដីពីបញ្ហានេះ ។

ជារួមគឺបំពេញរាល់មុខងាររដ្ឋបាល និងគ្រប់គ្រងទាំងឡាយ ដែលត្រូវបានប្រគល់ជូន ដោយបទបញ្ជាផ្ទៃក្នុងរបស់ **ខសកក** និងដោយសេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាល ។

១១.២. នាយក **ខសកក** ជាតំណាងវិទ្យាស្ថាន ចំពោះមុខតតិយជនទាំងឡាយ ។

១១.៣. នាយក **ខសកក** ត្រូវអនុវត្តគោលនយោបាយ និងសេចក្តីសំរេចទាំងឡាយ របស់ក្រុមប្រឹក្សាភិបាល ព្រមទាំងរាយការណ៍ អំពីការអនុវត្តន៍ ។

១១.៤. នាយក **ខសកក** ត្រូវស្នើទៅក្រុមប្រឹក្សាភិបាលសុំតែងតាំងនាយករងមួយរូប ឬច្រើនរូប ដើម្បីជួយការងាររបស់ខ្លួន ។

## ផ្នែកទី ៣

## បុគ្គលិករបស់ « ខសកក »

**មាត្រា១២.–**

**១២.១.** បុគ្គលិកអចិន្ត្រៃយ៍របស់ **ខសកក** រួមមានមន្ត្រីរាជការក្របខ័ណ្ឌមុខងារសាធារណៈ មកពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ឬពីក្រសួងមានសមត្ថកិច្ចផ្សេងៗផ្លាស់បញ្ចូលមក ឬដាក់នៅក្រៅតំណែង អម **ខសកក** តាមលក្ខខ័ណ្ឌដែលបានចែងក្នុងលិខិតបទដ្ឋាននានា ស្តីពីវិស័យមុខងារសាធារណៈ ឬជ្រើសរើសតាមសំណើ ឬដោយមានការយល់ព្រមពីនាយក **ខសកក** ។ មន្ត្រីទាំងនេះត្រូវបានរក្សាទុក នូវក្របខ័ណ្ឌប្រាក់បៀវត្ស និងប្រាក់កំរៃផ្សេងៗ ដែលបានកំណត់ដោយមុខងារសាធារណៈ ពីអង្គភាពដើមរបស់ខ្លួន ។

**១២.២.** វិទ្យាស្ថានអាចជ្រើសរើស ភ្នាក់ងារជាប់កិច្ចសន្យាជំនួយការ និងបុគ្គលិកអណ្តែត ។ ភ្នាក់ងារទាំងនេះត្រូវស្ថិតនៅក្រោមបទបញ្ញត្តិ នៃបទបញ្ជាផ្ទៃក្នុង និងសេចក្តីទាំងឡាយរបស់ក្រុមប្រឹក្សាភិបាល ។

**១២.៣.** បុគ្គលិក **ខសកក** ត្រូវគ្រប់គ្រងដោយបទបញ្ជាផ្ទៃក្នុង ដែលកំណត់ដោយក្រុមប្រឹក្សាភិបាល ។ បទបញ្ជាផ្ទៃក្នុង និងក្រុមប្រឹក្សាភិបាល កំណត់អំពីប្រាក់កំរៃលើកទឹកចិត្តចំពោះបុគ្គលិក ព្រមទាំងបែបបទនៃការទូទាត់ផង ។

## ផ្នែកទី ៤

## ទ្រព្យសម្បត្តិរបស់ « ទសកកក »

**មាត្រា១៣ .–**

**១៣.១. ទសកកក** ទទួលដើមទុនដំបូងពីរដ្ឋនូវអចលនវត្ថុដូចតទៅ :

–មជ្ឈមណ្ឌលស្រាវជ្រាវអភិវឌ្ឍន៍ដំណាំកៅស៊ូ មានផ្ទៃដី ៨៩៣.៥៥ ហិកតា ស្ថិតនៅឃុំជុប ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ដូចមានផែនទីបញ្ជាក់ទីតាំងភ្ជាប់ជាឧបសម្ព័ន្ធក្នុងអនុក្រឹត្យនេះ ។

–អគារមួយដែលប្រើប្រាស់ជាមន្ទីរពិសោធន៍ជាតិ ពិនិត្យ និងវាយតម្លៃគុណភាពជ័រកៅស៊ូ ស្ថិតនៅលើដីឡូត៍លេខ៩ ផ្លូវតឹមអ៊ីលស៊ុង សង្កាត់បឹងកក់១ ខ័ណ្ឌទួលគោក ក្រុងភ្នំពេញ ។

–អគារមួយដែលបំរុងធ្វើជាទីស្នាក់ការកណ្តាលនៃ **ទសកកក** ស្ថិតនៅលើដីឡូត៍លេខ ៧៥ ផ្លូវលេខ៥៧ សង្កាត់បឹងកេងកង១ ខ័ណ្ឌចំការមន ក្រុងភ្នំពេញ ។

**១៣.២.** ក្រៅពីអចលនទ្រព្យខាងលើ **ទសកកក** ត្រូវបានទទួលនូវចលនទ្រព្យផ្សេងៗ ដែលកំពុងប្រើប្រាស់ពេលបច្ចុប្បន្ន ។

**១៣.៣.** អចលនទ្រព្យ និងចលនទ្រព្យទាំងអស់របស់ **ទសកកក** នឹងមានចែងលំអិតក្នុងបញ្ជីសារពើភ័ណ្ឌ ។

**១៣.៤.** វិទ្យាស្ថានអាចទិញ-លក់ ចលនទ្រព្យ និង អចលនទ្រព្យ ចាំបាច់សំរាប់ដំណើរការរបស់ខ្លួន ។

## ផ្នែកទី ៥

## ការគ្រប់គ្រងហិរញ្ញវត្ថុ និងគណនេយ្យរបស់ « ទសកកក »

**មាត្រា១៤.–** ការគ្រប់គ្រងហិរញ្ញវត្ថុ និងគណនេយ្យនៃ **ទសកកក** ត្រូវប្រព្រឹត្តិស្របតាមគោលការណ៍ នៃគណនេយ្យសាធារណៈ ដូចមានចែងនៅក្នុងមាត្រា១២២ នៃអនុក្រឹត្យលេខ៨២ ចុះថ្ងៃទី១៦ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ ។

**មាត្រា១៥ .–** នាយក **ទសកកក** ជាអាណាប័កចំបងក្នុងការចំណាយថវិកានៃវិទ្យាស្ថាន ។

១៥.១. ក្នុងន័យនេះ និងអនុលោមតាមបទបញ្ជាផ្ទៃក្នុងរបស់វិទ្យាស្ថាន នាយក **ទសភក** ត្រូវ :

- ពិនិត្យកត់ត្រា និងទូទាត់ប្រាក់ចំណូល
- ជំរះ និងបញ្ជាចំណាយ

១៥.២. នាយកអាចផ្តល់សិទ្ធិទៅអាណាប័កប្រតិភូ ១រូប ។ អាណាប័កចំបងអាចបង្កើតផ្នែកគ្រប់គ្រងចំណូល ឬប្រចាក់បុរេប្រទាន ដោយមានការយល់ព្រមពីភ្នាក់ងារគណនេយ្យ របស់វិទ្យាស្ថានផង ។

**មាត្រា១៦ .–**

១៦.១. ការគ្រប់គ្រងហិរញ្ញវត្ថុ និងការកាន់កាប់គណនេយ្យ ត្រូវប្រព្រឹត្តតាមបទបញ្ជាផ្ទៃក្នុងរបស់វិទ្យាស្ថាន ក្រោមការទទួលខុសត្រូវជាបុគ្គល និងជាប្រាក់កាស របស់ភ្នាក់ងារគណនេយ្យ ក្នុងឋានៈជាគណនេយ្យករសាធារណៈ ។ ភ្នាក់ងារនេះត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រី ក្រសួង ិច្ច និងហិរញ្ញវត្ថុ ហើយធ្វើសម្បថមុនទទួលតំណែងខ្លួន ។ ភ្នាក់ងារគណនេយ្យនេះ មានសិទ្ធិចូលរួមប្រជុំជាមួយក្រុមប្រឹក្សាភិបាលផ្តល់មតិ តែឥតមានសំឡេងឆ្នោតឡើយ ។

១៦.២. ភ្នាក់ងារគណនេយ្យត្រូវទទួលបន្ទុក :

- ប្រមូលប្រាក់ចំណូល
- ទូទាត់ប្រាក់ចំណាយ
- ថែរក្សា និងគ្រប់គ្រងមូលនិធិ និងធនធានវិទ្យាស្ថាន
- ថែរក្សាសក្ខីប័ត្រ និងកាន់កាប់គណនេយ្យ

១៦.៣. ភ្នាក់ងារគណនេយ្យ អាចប្រគល់សិទ្ធិទៅអោយអាជ្ញានុការីរបស់ខ្លួន ។

**មាត្រា១៧ .–**

១៧.១. ធនធានរបស់ **ទសភក** បានមកពី :

- ប្រាក់ឧបត្ថម្ភដំបូងរបស់រដ្ឋ នៅពេលបង្កើតវិទ្យាស្ថាន ។

-ឧបត្ថម្ភធននៃដំណើរការ និងឧបត្ថម្ភជាមូលធន ដែលមានចែងក្នុងថវិការដ្ឋ។

-ប្រាក់ឧបត្ថម្ភដែលបានមកពី អំណោយ និងអច្ច័យទាន ។

-ប្រាក់ខ្ចីបុលដោយវិទ្យាស្ថានផ្ទាល់ ឬប្រាក់ដែលរដ្ឋអោយខ្ចីបុល ។

-ចំណូលពីការងារ និងការផ្តល់សេវាកម្មនៃ **ទសភក** ។

-ប្រាក់កាតព្វកិច្ចពីគ្រប់អតិថិជន និងអ្នកវិនិយោគដំណាំកៅស៊ូទាំងរដ្ឋ និងឯកជន លើទឹកដីកម្ពុជា ។

-ប្រាក់កំរៃដែលបានមកពីការលក់ ឬការជួលចលនវត្ថុ ឬអចលនវត្ថុ របស់ **ទសភក** ។

**១៧.២.** ចំណូល និងចំណាយជាប្រក្រតី ឬចំណូលនិងចំណាយជាដើមទុនរបស់ **ទសភក** ត្រូវបានគ្រោងក្នុងថវិកាប្រចាំឆ្នាំរបស់វិទ្យាស្ថាន ។ បទបញ្ជាផ្ទៃក្នុង នៃវិទ្យាស្ថាន ត្រូវបញ្ជាក់អំពីបែបបទនៃការរៀបចំនិងការអនុវត្តន៍ថវិកា ។

**១៧.៣.** ថវិកាត្រូវរៀបចំដោយអាណាប័កចំបងនៃ **ទសភក** ហើយត្រូវដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យសំរេច ។ ថវិកាត្រូវមានលំនឹង រវាងចំណូលនិងចំណាយ ។ ក្រុមប្រឹក្សាភិបាល ត្រូវអនុម័តគំរោងថវិកានេះអោយបានមុនថ្ងៃ៣០ ខែ កញ្ញា រៀងរាល់ឆ្នាំ ។

**មាត្រា១៨ .-**

**១៨.១.** គណនេយ្យរបស់ **ទសភក** រួមមានៈ

-គណនេយ្យទូទៅ តាមបែបបទទ្វេភាគ សំរាប់កត់ត្រាប្រតិបត្តិការផ្នែកថវិកា ផ្នែករតនាគារ និងជាមួយតតិយជន ។

-គណនេយ្យ អចលនវត្ថុ រូបធាតុ និងទ្រព្យ ។

-គណនេយ្យវិភាគ (ប្រសិនបើចាំបាច់ ) ។

គណនេយ្យវិទ្យាស្ថាន ត្រូវអនុលោមតាមវិធាននៃប្រកាស របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងគោរពនូវគំរោងគណនេយ្យរបស់ **វសកក** កំណត់ដោយក្រុមប្រឹក្សាភិបាល ហើយដែលបានទទួលការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

១៨.២. គណនីហិរញ្ញវត្ថុប្រចាំឆ្នាំរបស់វិទ្យាស្ថាន ត្រូវរៀបចំដោយភ្នាក់ងារគណនេយ្យ ហើយត្រូវដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យតាមរយៈនាយក ដោយមានភ្ជាប់នូវរបាយការណ៍ ស្តីពីការគ្រប់គ្រងរបស់ខ្លួន ។ ក្រុមប្រឹក្សាភិបាលធ្វើការអនុម័តក្នុងរយៈពេលយ៉ាងយូរ ៣ខែ ក្រោយពេលបិទការិយបរិច្ឆេទគណនេយ្យទាំងឡាយនេះ ។

**មាត្រា១៩ .**_មូលនិធិ នៃ **វសកក** ត្រូវតំកល់ក្នុងគណនីចរន្តនៅធនាគារប្រតិស្រុតណាមួយ ។

## ផ្នែកទី ៦

## របបសារពើពន្ធ និង ពន្ធគយ

**មាត្រា២០.**_ លើកលែងបទបញ្ញត្តិផ្ទុយពីនេះ **វសកក** ត្រូវស្ថិតនៅក្រោមរបបពន្ធគយ និងពន្ធអាករទាំងឡាយ ស្របតាមច្បាប់ជាធរមាន ដូចគ្នានឹងអង្គភាពរដ្ឋបាលផ្សេងៗទៀតដែរ ។

## ផ្នែកទី ៧

## លទ្ធកម្ម របស់ « វសកក »

**មាត្រា២១.**_ការសំរេច ការអនុវត្តន៍ និងការត្រួតពិនិត្យលទ្ធកម្មរបស់ **វសកក** ត្រូវគ្រប់គ្រងតាមបទបញ្ញត្តិ នៃអនុក្រឹត្យលេខ ៦០ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ ១៩៩៥ ស្តីពីការគ្រប់គ្រង លទ្ធកម្មសាធារណៈ និងច្បាប់ផ្សេងទៀត ស្តីពីចំណុចនេះ ។

## ជំពូកទី៣

### អាណាព្យាបាលលើ « ទសកកក »

**មាត្រា២២.**– **ទសកកក** ស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេស នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ និងក្រោមអាណាព្យាបាលហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា២៣.**–

**២៣.១.** **ទសកកក** ត្រូវផ្ញើជូនទីស្ដីការគណៈរដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងមន្ត្រីត្រួតពិនិត្យ ហិរញ្ញវត្ថុ នូវឯកសារ ដូចតទៅ :

–កំណត់ហេតុ កិច្ចប្រជុំនៃក្រុមប្រឹក្សាភិបាល

–គំរោងអភិវឌ្ឍន៍របស់វិទ្យាស្ថាន

–ថវិកាប្រចាំឆ្នាំ

–របាយការណ៍ គ្រប់គ្រង និងគណនី ហិរញ្ញវត្ថុប្រចាំឆ្នាំ

**២៣.២.** ឯកសារទាំងនេះ ត្រូវផ្ញើជូនតម្បជនដូចខាងលើនេះយ៉ាងយូរ ១៥ថ្ងៃ ក្រោយថ្ងៃបិទកាលបរិច្ឆេទ នៃឯកសារទាំងនេះ ។

## ផ្នែក ទី ១

### អាណាព្យាបាលបច្ចេកទេស

**មាត្រា២៤.**–

**២៤.១.** គំរោងអភិវឌ្ឍន៍ ឬថវិកាប្រចាំឆ្នាំនៃ **ទសកកក** ត្រូវផ្ញើជូនរដ្ឋមន្ត្រី ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយនាយក **ទសកកក** ក្នុងរយៈពេល ១៥ថ្ងៃ ក្រោយការអនុម័ត នៃក្រុមប្រឹក្សាភិបាល ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវផ្ដល់មតិទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ក្នុងរយៈពេលយ៉ាងយូរ ១ខែ ចាប់ពីថ្ងៃទទួលឯកសារខាងលើនេះ ។ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ត្រូវផ្ដល់ការយល់ព្រមក្នុងរយៈពេល ២ខែ ចាប់ពីថ្ងៃទទួលឯកសារទាំងនេះ ។

២៤.២. លិខិតផ្តល់ការយល់ព្រម ចុះហត្ថលេខាដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ឬតំណាងត្រូវផ្ញើជូនទៅនាយក **ទសគក** និងត្រូវចំលងជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ នាយក **ទសគក** ត្រូវបញ្ជូនពត៌មាននេះអោយក្រុមប្រឹក្សាភិបាលបានជ្រាបយ៉ាងឆាប់បំផុត ។

ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ មិនបានឆ្លើយតបក្នុងរយៈពេលកំណត់ខាងលើ គំរោងអភិវឌ្ឍន៍ ឬថវិកាប្រចាំឆ្នាំត្រូវចាត់ទុកថាបានទទួលការឯកភាពពីរដ្ឋមន្ត្រីនេះហើយ ។ ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ មានយោបល់ជំទាស់ ក្រុមប្រឹក្សាភិបាលត្រូវប្រជុំគ្នាអោយបានឆាប់រហ័សបំផុត ដើម្បីរកមធ្យោបាយដោះស្រាយបញ្ហានេះ ។

គំរោងអភិវឌ្ឍន៍ នៃ **ទសគក** មិនអាចអនុវត្តបាន បើសិននៅមានការមិនចុះសំរុងពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ថវិកាចំណាយប្រក្រតីត្រូវអនុវត្តផ្អែកលើ «ប្រព័ន្ធបែងចែកជា ១២ខែ » បើសិនជារដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅតែមានមតិមិនចុះសំរុងតទៅទៀត ។

**មាត្រា២៥.–**

**២៥.១.** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាចមានយោបល់ជំទាស់លើឯកសារដែលបានទទួល ដូចមានចែងក្នុងមាត្រា ២៣ខាងលើនេះ ហើយមានរយៈពេល ១ខែ ដើម្បីលើកមតិជំទាស់លើឯកសារទាំងនេះ ។

**២៥.២.** នាយក **ទសគក** ត្រូវជូនពត៌មានទៅដល់ក្រុមប្រឹក្សាភិបាល នូវខ្លឹមសារនៃការជំទាស់របស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ក្នុងសម័យប្រជុំយ៉ាងឆាប់មួយ ។ ក្រុមប្រឹក្សាភិបាល ត្រូវពិភាក្សារកមធ្យោបាយ ដើម្បីដោះស្រាយអោយបានឆាប់រហ័ស ។ ប្រសិនបើក្រុមប្រឹក្សាភិបាលសំរេចពុំយកជាការ នូវខ្លឹមសារនៃការជំទាស់ទាំងនោះ ក្រុមប្រឹក្សាភិបាលត្រូវធ្វើសេចក្តីពន្យល់ជាលាយលក្ខអក្សរ ជំរាបជូនដំណឹងជាបន្ទាន់ភ្លាម ទៅរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

មាត្រា២៦.–

២៦.១. រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាចបដិសេធ ឬផ្អាករាល់សេចក្តីសំរេចរបស់វិទ្យាស្ថាន ដែលមិនស្របតាមភារកិច្ចរបស់វិទ្យាស្ថាន ហើយដែលផ្ទុយនឹងច្បាប់ ឬបទបញ្ញាផ្សេងៗ ។

២៦.២. ការបដិសេធ ឬការផ្អាក ត្រូវបានសំរេចដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមការផ្តើមគំនិតរបស់ខ្លួន ឬតាមការស្នើសុំពីភាគីពាក់ព័ន្ធ ។ ការបដិសេធឬការផ្អាកនេះ ត្រូវបានជូនដំណឹងជាលាយល័ក្ខអក្សរទៅនាយក **ទសកក** ដែលនឹងត្រូវជូនដំណឹងជាបន្ទាន់ ទៅក្រុមប្រឹក្សាភិបាល ។

មាត្រា២៧.– រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសិទ្ធិសុំអោយមានការត្រួតពិនិត្យ **ទសកក** តាមតំរូវការនិងស្របតាមល័ក្ខខ័ណ្ឌ ដែលមានចែងនៅក្នុងច្បាប់ពាក់ព័ន្ធនឹងកិច្ចការត្រួតពិនិត្យនេះ ។

## ផ្នែកទី២

## អាណាព្យាបាលហិរញ្ញវត្ថុ

មាត្រា២៨.–

២៨.១. គំរោងអភិវឌ្ឍន៍ ឬថវិកាប្រចាំឆ្នាំ ត្រូវផ្ញើជូនរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយនាយក **ទសកក** ក្នុងរយៈពេល១៥ថ្ងៃ ក្រោយការអនុម័តនៃក្រុមប្រឹក្សាភិបាល ។ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវផ្តល់មតិទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងរយៈពេលយ៉ាងយូរ ១ខែ ចាប់ពីថ្ងៃទទួលឯកសារខាងលើនេះ ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវផ្តល់ការយល់ព្រមក្នុងរយៈពេល ២ខែ ចាប់ពីថ្ងៃទទួលឯកសារខាងលើនេះ ។

២៨.២. លិខិតផ្តល់ការឯកភាព ត្រូវចុះហត្ថលេខាដោយ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬតំណាងត្រូវផ្ញើទៅនាយក **ទសកក** ដោយមានចំលងជូនរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ។ នាយក **ទសកក** ត្រូវជូនដំណឹងនេះដល់ក្រុមប្រឹក្សាភិបាលយ៉ាងឆាប់បំផុត ។

ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មិនបានឆ្លើយតបក្នុងរយៈពេលដូចបានកំណត់ខាងលើ គំរោងអភិវឌ្ឍន៍ ឬថវិកាប្រចាំឆ្នាំត្រូវចាត់ទុកថាមានការឯកភាពពីរដ្ឋមន្ត្រីនេះហើយ ។ ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានយោបល់ជំទាស់ ប្រធានក្រុមប្រឹក្សាភិបាល ត្រូវកោះប្រជុំក្រុមប្រឹក្សាភិបាល អោយបានឆាប់រហ័ស ដើម្បីរកមធ្យោបាយដោះស្រាយបញ្ហានេះ ។

របាយការណ៍ស្តីពីការគ្រប់គ្រងនិងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំទាំងឡាយ ត្រូវចាត់ទុកថាគ្មានការយល់ព្រម បើសិនជាការមិនចុះសំរុងរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មិនទាន់ត្រូវដោះស្រាយបាន ។

**មាត្រា២៩.–** លិខិតដូចខាងក្រោមនេះរបស់ក្រុមប្រឹក្សាភិបាល ឬនាយក **ទសគក** ត្រូវដាក់សុំការឯកភាពពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឆ្លងតាមយោបល់របស់រដ្ឋមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ :

–ការលក់អចលនទ្រព្យ

–ការលុបចោលនូវឥណទេយ្យ ដែលមានទឹកប្រាក់លើសកំរិតទឹកប្រាក់មួយមានកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

–ការសំរេចខ្ចីបុល ឬកិច្ចព្រមព្រៀងធានា ឬលិខិតស្នាម ដែលមានកម្មវត្ថុប្រហាក់ប្រហែលគ្នានេះ ។

**មាត្រា៣០.–** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវតែងតាំងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុប្រចាំ **ទសគក** ។ មន្ត្រីនេះមានភារកិច្ចត្រួតពិនិត្យ មុនធ្វើនិងក្រោយធ្វើ ស្របតាមអនុក្រឹត្យលេខ ៨១ ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិកាក្រសួង ខេត្ត-ក្រុង និង អង្គការសាធារណរដ្ឋបាលទូទៅ ។

**មាត្រា៣១.–**

**៣១.១.** ការគ្រប់គ្រងដោយអាណាប័កចំបងនៃ **ទសគក** ស្ថិតនៅក្រោមការត្រួតពិនិត្យ នៃអគ្គាធិការដ្ឋានហិរញ្ញវត្ថុ ។

៣១.២. ការគ្រប់គ្រងរបស់ភ្នាក់ងារគណនេយ្យ ត្រូវស្ថិតក្រោមការត្រួតពិនិត្យនៃគណនេយ្យ កណ្តាលរបស់ធនាគារជាតិ និងក្រោមការត្រួតពិនិត្យនៃអគ្គាធិការដ្ឋានហិរញ្ញវត្ថុ ។

៣១.៣. រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចាត់តាំងអោយមានការត្រួតពិនិត្យរួមអធិការកិច្ច ឬពិនិត្យលើផ្នែកណាមួយ ដែលយល់ថាចាំបាច់ ក្នុងល័ក្ខខ័ណ្ឌដែលមានចែងក្នុងច្បាប់ពាក់ព័ន្ធ នឹងកិច្ចត្រួតពិនិត្យនេះ ។

## ជំពូកទី ៤

## អវសានបញ្ញត្តិ

**មាត្រា៣២.–**

៣២.១. បទបញ្ញត្តិទាំងឡាយ ដែលមានពីមុន ហើយផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

៣២.២. សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងស្ថាប័នដែលមានការពាក់ព័ន្ធ ត្រូវអនុវត្តអោយបានសំរេចនូវអនុក្រឹត្យនេះ ។

៣២.៣. អនុក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និង ត្រា

**អ៊ុង ហួត** **ហ៊ុន សែន**

* * *

## អនុក្រឹត្យ លេខ ៦៦ អនក្រ.បក

## ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

## រាជរដ្ឋាភិបាល

–បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា